002/19-09-2007-ECCC/TC
E1/331

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 24 / 08 / 2015
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

**សាធារណៈ**

# សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

# ថ្ងៃ ច័ន្ទ ទី ១៧ ខែ សីហា ឆ្នាំ ២០១៥

# សវនាការលើភ័ស្តុតាង - ថ្ងៃ ៣១២

រៀបចំដោយ៖ **សែ កុលវុឌ្ឍី** និង **Roger PHILLIPS**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុល(ប្រធាន) , ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី, ចៅក្រម យូរ ឧត្តរា (អវត្តមាន) |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត, លោក Vincent de WILDE d'ESTMAEL, លោក ស្រ៊ា រតនៈ, លោក Nicholas KOUMJIAN, លោក Joseph ANDREW BOYLE |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin |

| SAUNDERS |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោកស្រី ទី ស្រ៊ីនណា, លោក ពេជ អង្គ, លោក វ៉ែន ពៅ |
| សាក្សី/ដើមបណ្តឹង៖ លោក ឈិត យឿក (2-TCW-937), លោក ឈុំ សេង (2-TCW-828) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ លោក ឡុញ ង៉ែត, កញ្ញា សុក សុភ័គមណីកា, លោក វ៉ាត សុម៉ៅ, លោក ឡាយ ណាវ៉ា, កញ្ញា ស៊ីម សុខជា, កញ្ញា Aphra LEE |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០១ | បញ្ចប់ម៉ោង៖ ១៦.០១ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.០៧ | បញ្ចប់ម៉ោង៖ ១០.២៨ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.១៨ | បញ្ចប់ម៉ោង៖ ១៣.២៩ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៤.៥៨ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង និង ១០ នាទី |

| **<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០២ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៤ | ០៩.០៥ |
| ការតាំងសំណួរទៅសាក្សី ឈិត យឿក (2-TCW-937) | មេធាវីការពារក្តី នួន ជា<br><br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៦<br>១០.២៩<br>១០.៥៦<br>១១.០៥ | ១០.០៧<br>១០.៥៥<br>១១.០៤<br>១១.១៥ |

| | | | |
|---|---|---|---|
| វិសាលភាពនៃការជំនុំជម្រះក្ដីទាក់ទងនឹងអតីតមន្ត្រីរដ្ឋការស៊ីវិលនៃរបបសាធារណៈរដ្ឋខ្មែរ | មេធាវីការពារក្ដី នួន ជា<br>អង្គជំនុំជម្រះ | ១៤.៣២<br>១៤.៣៥ | ១៤.៣៣<br>១៤.៣៦ |
| ការតាំងសំណួរទៅសាក្សី ឃុំ សេង<br>(2-TCW-828) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១៣.៣២<br>១៣.៤២<br>១៤.២៥<br>១៥.០៧ | ១៣.៤១<br>១៤.២៤<br>១៤.៤០<br>១៥.៥៩ |

<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>

<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

<u>ការតាំងសំណួរទៅសាក្សី ឈិត យឿក (2-TCW-937)</u>

មេធាវីការពារក្ដី នួន ជា និង មេធាវីការពារក្ដី ខៀវ សំផន បានធ្វើការតាំងសំណួរទៅសាក្សី ឈិត យឿក។

<u>វិសាលភាពនៃការជំនុំជម្រះក្ដីទាក់ទងនឹងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរ</u>

សហព្រះរាជអាជ្ញាបានតាំងសំណួរទៅសាក្សីទាក់ទងនឹងទាហាន លន់ នល់ ដែលបានកំណត់គោលដៅដោយខ្មែរក្រហម ដែលធ្វើឱ្យមានការជំទាស់ពីមេធាវីការពារក្ដី នួន ជា។ មេធាវីការពារក្ដី បានថ្លែងថាការតាំងសំណួរដោយសហព្រះរាជអាជ្ញា គឺផ្ទុយទាំងស្រុងទៅនឹងសេចក្ដីសម្រេចដែលបានកំណត់នៅក្នុងឯកសារ E315 ដែលបានបញ្ជាក់ថា ការប្រព្រឹត្តិលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺកំណត់ត្រឹមតែ សហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា មន្ទីរសន្តិសុខក្រាំងតាចាន់ និង មន្ទីរសន្តិសុខស-២១។ ហេតុដូច្នេះ ការតាំងសំណួរនេះស្ថិតនៅក្រៅវិសាលភាពនៃអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម។

សហព្រះរាជអាជ្ញា បានលើកឡើងថា ការតាំងសំណួរនេះគឺបញ្ជាក់ពីភាពខុសគ្នារវាង កម្មាភិបាលពាយ័ព្យ និងកម្មាភិបាលនិរតី។ ការផ្តោតនៃការតាំងសំណួរនេះ គឺថាហេតុអ្វីបានជាសាក្សីនៅពេលដែលនិយាយអំពីកម្រិតនៃការអត់ឃ្លាន ដោយសារតែពេលនោះ កម្មាភិបាលភូមិភាគនិរតី មិនទាន់ចូលមកដល់ទីតាំងនេះឬក៏យ៉ាងណា។

អង្គជំនុំជម្រះបានបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី នួន ជា ចំពោះសំណួរនេះ និងបានលើកឡើងថា សំណួរនេះ គឺពាក់ព័ន្ធទៅអង្គហេតុនៃការបោសសម្អាត។

មេធាវីការពារក្តី ខៀវ សំផន ស្នើសុំការបញ្ជាក់ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ និងបានចោទសួរពីវិសាលភាពនៃការជំនុំជម្រះដែលបានពន្លាតរហូតដល់គោលនយោបាយនៃការប្រព្រឹត្តិទៅលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ សហព្រះរាជអាជ្ញា បានឆ្លើយតបថា មានមធ្យោបាយពីរដែលបង្ហាញថាមានអត្ថិភាពនៃគោលនយោបាយ ដោយការណែនាំ និងការបញ្ជាចុះមកក្រោម ឬក៏ពីខាងក្រោមនៅមូលដ្ឋាន។ ប៉ុន្តែសំណួរដែលជំទាស់នេះ គឺជាសំណួរដែលពាក់ព័ន្ធទៅនឹងភាពខុសគ្នារវាងកម្មាភិបាលពាយ័ព្យ ហើយនិងនិរតីបន្ទាប់ពីពួកនិរតីចូលមកដល់ភូមិភាគពាយ័ព្យ នៅក្នុងបរិបទនៃការបោសសម្អាត។ ដូចនេះ មិនគួរណាពិភាក្សាគ្នាវែងឆ្ងាយនោះទេ។

សហមេធាវីនាំមុខ បានគូសបញ្ជាក់ថា អង្គជំនុំជម្រះនឹងមានការសម្រេចអំពីអត្ថិភាពនៃគោលនយោបាយនៅថ្នាក់ជាតិ ហើយបន្ទាប់មកទៀត ការប្រព្រឹត្តឧក្រិដ្ឋកម្មដែលកើតចេញពីការអនុវត្តគោលនយោបាយទាំងអស់នេះ នៅទីតាំងឧក្រិដ្ឋកម្មមួយចំនួន។ សហមេធាវីនាំមុខ បានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលថា ការតាំងសំណួរអាចធ្វើជាទូទៅបានទាក់ទងទៅនឹងអត្ថិភាពនៃគោលនយោបាយទាំងនេះ។

ចៅក្រម Jean-Marc LAVERGNE បានឆ្លើយតបទៅនឹងការសង្កេតទាំងនេះ និងបាននិយាយថា អង្គជំនុំជម្រះនឹងមិនធ្វើការអត្ថាធិប្បាយវែងឆ្ងាយទាក់ទងនឹងការកត់សម្គាល់នេះទេ ដូចដែលអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចច្បាស់លាស់រួចហើយ ទៅលើការជំទាស់ដែលបានលើកឡើងនេះ។

**<u>ការតាំងសំណួរទៅសាក្សី ឈុំ សេង (2-TCW-828)</u>**

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួន ទាក់ទងនឹងអត្តសញ្ញាណរបស់សាក្សី ព្រមទាំងប្រាប់អំពីសិទ្ធិ និងករណីកិច្ចទៅសាក្សី ឈុំ សេង (2-TCW-828)។ បន្ទាប់មក សហព្រះរាជអាជ្ញាបានធ្វើការតាំងសំណួរជាបន្ត។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9076 | E305/13.23.368 | 00728841-00728896; 00731151-00731190 | Statement of MUN Mut alias MUN Saroeun (DC-Cam) | P | 00728868 00728869 00728870 | 00731170 00731172 | N/A |
| E127/7.1.6 | D119/33 | 00907522-00907530; 00923043-00923050; 00988634-00988642 | Written Record of Interview of CHHIT Yoeuk | P | 00988637 00988638 | 00923045 00923046 | 00907525 00907526 |
| E3/9010 | E305/13.23.308 | 00730759-00730816; 00728608-00728640; 01123575-01123605 | Statement of CHHUM Seng (DC-Cam) | P | 00730761 00730800 | 00728610 00728632 | 01123577 01123598 |
| E3/9008 | E305/13.23.306 | 00728770-00728840; 00731105-00731150; 01123704-01123742 | Statement of CHHIT Yoeuk (DC-Cam) | P | 00728796 00728797 00728798 00728815 00728816 00728822 00728823 00728824 00728832 00728883 | 00731123 00731124 00731135 00731140 00731145 00731146 00731139 | 01123720 01123721 01123729 00112330 01123732 01123733 01123738 |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/178 | D175/4.3 | 00275587-00275598; 00342708-00342723; 00623304-00623321 | Weekly Report of Region 5 Committee, 21 May 1977 | P | 00275587 | 00342708 | 00623304 |
| E3/9094 | E305/13.23.384 | 00734030-00734120; 00728641-00728705; 01123606-01123663 | Statement of PAN Chhuong (DC-Cam) | C | 00734089 | 00728683 | 01123644 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៦)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផនទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥។ (១៦.០០)

**<u>កាលវេលាសវនាការបន្ត</u>**

សវនាការនឹងបន្តទៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលទុឡឺ** **Roger PHILLIPS**